# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ២៦៦២ សហវ.ហវ

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១០

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**

**កម្មវត្ថុ:** ករណីសំណើសុំថវិកាចំនួន ៨៩៣.០៨៧,៧០ ដុល្លារអាមេរិក សម្រាប់ជួសជុល និងស្តារឡើងវិញនូវប្រឡាយមេប៉ាន់ណោ (ដំណាក់កាលទី២) ក្រោមឥណទានកម្មវិធី ADB 2022-CAM(SF) ។

**យោង:** លិខិតលេខ ១២៥៦ ធទឧ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០ របស់ក្រសួងធនធានទឹក និងឧតុនិយម ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមឯកឧត្តមមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាពជាគោលការណ៍ផ្តល់នូវថវិកាបន្ថែមក្នុងកំរិតអតិបរមា ៤៣០.០០០ ដុល្លារអាមេរិក (បួនរយសាមសិបពាន់ដុល្លារអាមេរិក) ជូនក្រសួងធនធានទឹក និងឧតុនិយម ដោយត្រូវធ្វើការចរចា និងធ្វើវិសោធនកម្មកិច្ចសន្យាជួសជុល និងស្តារឡើងវិញប្រឡាយមេប៉ាន់ណោជាមួយក្រុមហ៊ុនដែលកំពុងអនុវត្តកិច្ចសន្យានេះ សម្រាប់ការងារបន្ថែមដូចខាងក្រោម:

១ - ពង្រីកទទឹងខ្នងទំនប់ ២ ម៉ែត្រ បន្ថែមទៀត ទឹកប្រាក់ចំនួន ១៦០.០០០ ដុល្លារអាមេរិក

២ - សាងសង់លូប្រអប់សង្ខាងប្រឡាយចំនួន ៣ កន្លែង ទឹកប្រាក់ចំនួន ១៥០.០០០ ដុល្លារអាមេរិក

៣ - សាងសង់លូមូលសង្ខាងប្រឡាយចំនួន ៣ កន្លែង ទឹកប្រាក់ចំនួន ១២០.០០០ ដុល្លារអាមេរិក

ដោយប្រើប្រាស់ថវិកាក្រោមក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការរបស់ ADB លេខ 2585-CAM (SF) ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្ត តាមការគួរ ។

សូមឯកឧត្តមមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

*ចម្លងជូន :*

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ
  **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- មន្ទីរធនធានទឹក និងឧតុនិយមខេត្តកណ្តាល
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកណ្តាល
- ឯកសារ - កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨